


# កំណាព្យរបស់ធម្មាចារ្យ ធឹង កាន

# អានដោយធម្មាចារ្យ ប៊ុត សាវង្ស

១.ព្រះធម៌មិនស្តាប់ច្បាប់មិនអាន    ចេះចាំនិងមានមកពីណា
ខ្លួនឯងមិនស្វែងជោគវាសនា    សង្ឃឹមទេវតាគេអាណិត។
២.មានះជើងឯកប៉ែកខាងរឹង    លូង់ម្លឹងគង់មិនព្រមញ៉ុមអ្នកណា
មានះនេះមានដរាបណា    ប្រយោជន៍ខ្លឹមសារត្រូវអន្តរាយ។
៣.ខាងឃើញមុខម៉ែមានទៅទាស់អី    កុំតែបាត់មុខប្តីឬឱអាង៉ា
ខានឃើញមុខឱគ្មានបញ្ហា    កុំតែបាត់ភក្ត្រាម៉ែអាទូច។
គំនិតបែបនឹងច្បាប់លោកថា    ចូលក្បួនបរាគេចមិនរួច
តែមិនរហ័សច្បាស់ជាធ្លូច    ត្រូវចេះកំហូចវាផ្គន្ទា។

## ៤. ស្រណោះម្តាយថ្ងូរម៉ែស្រែក

គួរអាសូរចិត្តអាណិតម៉ែ    អស់៩ខែម៉ែពរផ្ទៃ
ស៊ូទ្រាំចាញ់គភ៌ញ័រល្ហិតល្ហៃ    អាស្រ័យបុត្រភ្ងាផ្ញើជីវិត។
ម្លឹងហើយម៉ែនៅនឹកស្រឡាញ់    លំបាកម្តេចមិញឥតបើគិត

ទន្ទឹងឲ្យតែខែមកដិត ពិតចង់ឃើញបុត្រពិសី។
ពេលឆ្លងទន្លេម៉ែឈឺណាស់ ឈឺក្រៃឈឺក្រាស់ហួសឧបមេយ្យ
ស្ទើរផុតជីវិតចាកលោកកិយ វិស័យមច្ចុរាជមករង់ចាំ។
បើម៉ែបានឆ្លងផុតវាលធំ ម៉ែស្តាប់កូនយំម៉ែចំណាំ
សំឡេងកូនតូចដូចបណ្តាំ ផ្សះផ្សាំទ្រូងម៉ែឲ្យល្ហែពិត។
ម៉ែចិញ្ចឹមកូនម៉ែថ្នាក់ថ្នម បំពេរបីបមលោមប្រណីត
ឆ្លងកាត់តំណក់នៃលោហិត ផ្ចិតដោយឱរាដ៏ថ្លាស្អាត។

## ៥. ស្រណោះព្រលឹងម៉ែអាសូរចិត្តម្តាយ

កាលវ័យទារក

ម៉ែថ្នមម៉ែបក់ មិនឲ្យមានឆ្គង អង្អែលស្រវា
ហត្ថាទាំងសង ធ្វើជាបង្គង ទ្រនំជីវិត។

ពេលម៉ែមានទុក្ខ

បណ្តាញស្នាញស្មុគ្រ ថ្លុកភពងងឹត បានយល់ភក្ត្រា
បុត្រភ្វាពិសិទ្ធ ម្តាយសប្បាយចិត្ត ផុតទុក្ខមួយគ្រា។

រីម៉ូត្រលាមក

គំរើក្អួតឈ្លក់ ក្រខ្វក់ម្តេចម្តា ម៉ែគ្មានខ្ពើមស្អប់
ឥតថប់ចិន្តា វិស័យដូចផ្កា ពិដោរធម្មជាតិ។

ពេលមានរោគា

ឈឺថ្កាត់នានា ម៉ែមិនចង់ឃ្លាត ទ្រូងម្តាយខ្លោចផ្សា
ឱរាចង្អៀត បែបន់អភិវាទ ឲ្យតែកូនជា។

គ្រាកុមារវ័យ

ចិត្តម្តាយរំពៃ ឲ្យកូនសិក្សា រៀនលេខអក្ខរៈ
សិល្បៈវិទ្យា រៀបចំវាសនា អនាគតរុងរឿង។

ទោះក្រយ៉ាងណា

ធ្វើស្រែចំការ កាយស្រូវចំបើង យកប្រាក់ឲ្យរៀន
ឲ្យប្រសើរឡើង ឲ្យបានកូនថ្កើង ស្មើមុខនឹងគេ។

ពេលវ័យបឋម

កំលោះក្រមុំ ពេញដូចដួងខែ ចិត្តម្តាយស្រទន់
គយគន់គ្នាន់គ្នេរ ចិត្តគួចល្បួចស្នេហ៍ សម្លស្សសោភ័ណ។

ពេលកូនប្រុសស្រី
មានប្រពន្ធប្ដី ចិត្តម្ដាយត្អេរត្អាន់ ចង់ឲ្យបានសុខ
ស៊ីចុកគ្រប់គ្រាន់ កុំបីរិះគន់ ឈ្លោះទាស់ទែងគ្នា។
កូនសុខសប្បាយ
ស្រុះស្រួលស្រស់ស្រាយ ម៉ែសប្បាចិត្ត ត្រង់ម្ដាយអត់ឃ្លាន
ម្ដាយគ្មានទាមទារ ឱះឱអនិច្ចា អាសូរម្ដាយខ្ញុំ។

## ៦. កុំស្រឡាញ់អ្នកដទៃជាងម៉ែកុំឃើញគេថាល្អជាងម្ដាយ

សូមក្រើនដល់កូនប្រុស ស្រីទាំងអស់គ្រប់ៗប្រាណ
ចូរអ្នកតាំងសន្ដាន កុំបានភ្លេចទុក្ខរបស់ម៉ែ។
បើអ្នកអាយុ ២០ សូមអ្នកលៃគិតរិះរេ
កាលយើងបានបីខែ តើម៉ែយើងធ្វើអ្វីខ្លះ។
ហៃកូនគ្រប់ប្រាណអើយ កុំព្រងើយចូររហ័ស
ម៉ែឪនៅលើផ្ទះ អ្នករៀសសន្សំបុណ្យ។

បានម្ហូបចំណីគាប់ ជូនគោរពអ្នកមានគុណ
ជូនគាត់ពិសាមុន អ្នកបានបុណ្យជាប្រាកដ។
សំពត់អាវស្លៀកពាក់ បើប្រលាក់បោកហាលបត់
រៀបចំល្អម៉ត់ចត់ នេះជាវត្តកូនទាំងឡាយ។
ម៉ែពុកមានជម្ងឺ រោគយាយីសកលកាយ
ផ្លាស់ប្ដូរបបរបាយ ចូរខ្វល់ខ្វាយថៃរក្សា។
ពេលជាទឹកនោះស្រាល ក្នុងពេលកាលមានរោគា
ទឹកស្រាលប្រែក្លាយជា ធ្ងន់ហត្ថាលើកពុំបាន។
រវាំងការរាក់ជ្រៅ មើលទីនៅទីសំរាន
សំរាមធូលីមាន បោសជូតលាងឲ្យស្អាតផង។
សូមអ្នកធ្វើតបគុណ ប្រសើរលន់ឥតសៅហ្មង
ល្អហើយបានបុណ្យផង ត្រង់គន្លងនៃកុសលា។
រីអស់ជនសប្បុរស ទោះជាមនុស្សឬទេវតា
សរសើរហើយរក្សា ជួយការពាររាល់ថ្ងៃខែ។
បានជាខ្ញុំរំលឹក អាណិតនឹកអស់ឪម៉ែ

នឹកដល់កូនផងដែរ  សូមរិះរេចារចែងចប់។
តែសូមផ្តាំចុងក្រោយ  បើថ្លោះធ្លោយសូមកុំស្អប់
សូមផ្តាំចាំឲ្យជាប់  សូមកុំស៊ីដប់សងមួយ។

៧. រឿងចាស់គ្មានសិទ្ធនឹងចៀសបាន គ្រប់ប្រាណតែងមានជាធម្មតា
ទោះលោមអង្វរសូកយ៉ាងណា  អស់ទាំងលោកាគ្មានផ្សារលក់។
រឿងឈឺឥតរើសរូបលខ្មៅ  ម៉ឺនសែនផ្សាក្តៅដូចភ្លើងភ្នក់
ឈឺតូចឈឺធំបំពត់  ខ្ទេចខ្ទាំដំគក់សរីរាង្គ។
ពេលស្លាប់ជាពេលអស់កម្មសិទ្ធ  ពេលនាំជីវិតចាកកាយា
ក្តីស្លាប់ឥតមានអ្នកត្រូវការ  តែមច្ចុមារមិនយោគយល់។
ម៉ែឪកូនចៅប្តីប្រពន្ធ  សង្សារទ្រព្យធនធ្លាប់ថ្កើងថ្កល់
ជាទីស្រឡាញ់ពេលនិយម  គង់ក្រោមឥទ្ធិពលក្តីប្រាស់ព្រាត់។
អ្នកអាក្រក់អ្នកល្អអ្នកសខ្មៅ  អ្នកឆ្លាតអ្នកខ្លៅអ្នកក្រខ្សត់
សុទ្ធតែមានកម្មជាបន្ទាត់  កំណត់ចែងចារវាសនាអើយ។
៨. អត្តភាពជាមនុស្សពេញហៅក្រ  កើតដោយផលល្អដែលយើងបាន
កសាងសន្សំយ៉ាងចំណាន  នាំយើងឲ្យបានភពជាមនុស្ស។

ក្រពីរគឺជីវិតការរស់នៅ  រស់ហើយត្រង់ផ្លូវនៃសប្បុរស
សន្សំសុចរិតឥតមានខ្ចោះ  នេះពិតជារស់ហើយល្អផង។
ដល់ក្រទីបីបានស្តាប់  ព្រះធម៌ជាច្បាប់ឥតសៅហ្មង
ព្រះធម៌យូរៗទើបមានម្តង  ក្រក្រៃកន្លងប្រាកដពិត។
ទីបួនកម្រក្រក្រៃណាស់  គឺក្របានត្រាស់ជាព្រះពុទ្ធ
ប្រសើរលើសលោកជោគវិសុទ្ធ  ឆ្លងផុតងងឹតគឺអវិជ្ជា ។
យោនរោរីនរៈទាំងឡាយអើយ  បានកើតមកហើយគ្រប់អង្គារ
ជាលាភឧត្តមធំមហិមា  ចូរអ្នកឧស្សាហ៍សាងដើមទុន
កុំបីលង់លក់វង្វេងភ្លេច  ចុះចាញ់កលល្បិចនៃកាមគុណ
គិតកាញ់កុំឲ្យចាញ់ជាតិមុន  តែស៊ុនដល់ស៊ិយគង់ស្តាយក្រោយ
សាងល្អក្រណាស់ដូចច្រាស់ទឹក  ប្រឹងល្ងាចប្រឹងព្រឹកកុំបណ្តោយ
ទោះទាំងទឹកភ្នែកជ្រែកក៏ដោយ  ចុងក្រោយផលបានក្សាន្តសុខា

៩. ទឹកមួយប្រលង់កុំក្បង់នឹងដៃ  នាំឲ្យចង្រៃល្អក់វរវឹក
គួរលុតជង្គង់បង្អោនក្រេបផឹក  ម្តេចបានមួយក្អឹកបំបាត់ខះក។
ជីវិតមានតិចកុំបិចធ្វើបាប  ថ្នាក់ថ្នមសុខភាពសម្រាប់សាងល្អ

សន្សំរឿងស្អាតសង្ខាតធម៌ស ឲ្យដូចរសស្ករក្សារសផ្អែម។

១០.ទឹកស្អុយទឹកជ្រាំផ្សំបានជាជី គ្រាប់ស្វាយចន្ទីលីងទទួលភ្ញៀវតុ
ត្រីស្អុយត្រីហើមផ្សំបានជាជី ធម៌នៅនឹងមុខសំកុកដល់ណា។

១១. លុយអើយៗលុយ មិនក្រអូបមិនស្អុយ ជាទីរាប់អាន
ទំរាំលុយដាច ធ្វើម្ចាស់ប៉ុន្មាន រ៉ាប់ចេះតែបាន
ឥតមានប្រកែក។
ទោះខ្វិតទោះខ្វាក់ អ្នកមានផុតថ្នាក់ ឬធុនដងវែក
ឲ្យតែស្មោះស្ម័គ្រ ប្រាក់មិនដែលស្រែក ទល់ខ្លួនរហែក
បាត់បង់រូបកាយ។
ចំនែកនាងមាស រាប់អានដោយផ្ទះ ឬយល់ភក្ត្រា
ទាល់តែអ្នកមាន ទើបមាសប្រាថ្នា អ្នកក្រឡេឡា
មាសថាទេៗ។
រីឯនាងពេជ្រ រស្មីព្រេចៗ អន្ទ្រើសលើសគេ
អ្នកមានព្រួលៗ ពេជ្រថាទេៗ ពេជ្រថាទាល់តែ

ម៉ាក្សសីដេសរ៉ុលវ៉ូ។

១២. ល្ហុងទុំក្រួចឆ្មាជាចំណីទាស់របស់អ្នកចាញ់បរ
កំសត់ក្រីក្រជាចំណីទាស់ជំពាក់គេ
ស្រ្តីរូបស្អាតជាចំណីទាស់របស់ប្រុសស្នេហ៍
ល្ងង់មិនកែប្រែជាចំណីទាស់របស់មនុស្សចចេស។

១៣. រកសប្បុរសថាមិនដឹងនៅឯណា រកផ្ទះអាចារ្យថាមិនស្គាល់
រកអ្នកទ្រង់សីលថាទៅមិនដល់ ស្តាប់ធម៌ថារវល់បោកភួយមុង
ថ្ងៃសីលថារវល់ជាប់ដេរកាត់ ថ្ងៃអាទិត្យថារវល់ឆាស្ងោរហុង
៨កើតថាជាប់ទៅទីក្រុង ពេញបូណ៌ថាប្រុងទៅចំការ
៨រោចថារវល់ក្រែមជាប់មាត់ ខែដាច់ថាមិនដឹងទៅវត្តណា
ពេលថ្ងៃថារវល់ចាត់ចែងការ ពេលយប់នោះថាសំរាកកាយ
នៅក្មេងថាទាស់ឯងក្រមុំ ចាស់ជំនុំថាទាស់ឯងមេម៉ាយ
ទៅវត្តក្រែងមាត់គេចំណាយ ថាមាននិស្ស័យនិងលោកសង្ឃ
មានប្តីថាទាស់និងពុកវា រីឯតាថាយាយមិនស្រួលអង្គ

ចំណែកមីងថាចោលកូនឲ្យរហង់ រីឯបងថាគ្មានមនុស្សចាំផ្ទះ។
ចូលឆ្នាំភ្ជុំបិណ្ឌគេទៅវត្ត ប្រតិបត្តិទាលសីលថ្វាយបង្គំព្រះ
ឯងឯណេះថាបានដាច់ឆ្នាំចាស់ ម្តងណេះគិតលះឲ្យអស់ដៃ។
ដល់ផ្លូវចូលវត្តហ្រាំងមិនស៊ី ហុងដាមីគីធីអាកៃ
ថាទៅវត្តនោះគ្មានតម្លៃ ឯកភ្នំៗសំពៅសប្បាយជាង។
បណ្តោយជីវិតតាមខ្សែញាក់ តណ្ហាជាអ្នកធ្លាក់រូបរាង
បើបានចូលវត្តអែបខាងៗ ព្រោះខ្លាចតឹនុយឯងមិនសម។
មើលអ្វីនិយាយអ្វីចេះតែបាន ទោះម៉ោងប៉ុន្មានមិនចាប់ខំ
អានច្បាប់ឬស្តាប់ព្រះសទ្ធម្ម តែមួយម៉ោងយ៉ាប់ទ្រាំអ្វីម្ល៉េះណា
ខែប្រាំប្រឹងមិនរួចថ្ងួចថាត្រក ខូចខុសខាតខកដល់វស្សា
ឆ្នាំវកថាចិត្តមិនជ្រះថ្លា ឆ្នាំរកាថាបញ្ហាមិនរសាយ។
បែបហ្នឹងកុំបឿងបានឋានសួគ៌ គាប់គួរដាក់ទុកញាតិអបាយ
ហែអស់ពួកយើងផងទាំងឡាយ ខ្វល់ខ្វាយដូរម៉ូតម្តងមើល៍!។

១៤.
ដូចចងអង្រឹងដេកលើចុងត្នោត អ្នកដេកនោះសោតស្រៀវប៉ុណ្ណា
អបាយភូមិគួរខ្លាចគួររអា ជាងការដេកអង្រឹងនោះទៅទៀត

១៥.
សម្តីពិរោះមានក្នុងអសប្បុរស ថ្នាំពិសចំរុះក្នុងទឹឃ្មុំ
រសឆ្ងាញ់មានជាតិពុលលាយទ្បំ បីនេះសូមផ្តាំត្រូវប្រយ័ត្ន។

១៦.
បើគេមិនចង់កុំចង់ជួសគេ រឿងនោះនាំតែកើតក្តីអម្ពល់
បើគេនោះចង់សឹមយើងខ្វាយខ្វល់ ការជាកុសលរវល់គាប់ហោង។

១៧
ពាក្យល្អអសប្បុរសមិនត្រូវការ ក្រៀលបក្សាមិនត្រូវផឹកទឹកដោះ
ស្ត្រីជាសត្រូវនឹងតាបស ដំរីខ្លាពស់ជាសត្រូវអ្នកដើរព្រៃ

១៨.
ថ្នាំពិសជាសត្រូវមុខដំបៅ មួម៉ៅជាសត្រូវសុខសេរី

កំពីងពួយជាសត្រូវសន្ទូងថ្មី ប្រពន្ធក្មេងជាសត្រូវនឹងប្តីចាស់។

១៩.

ឃើញអ្នកចេះគេរៀររបស់ណា គួរផ្តោតនេត្រាសោតាសណ្តាប់
បង្អោនគន់គិតដោយខ្លួនខ្ជាប់ ប្រញាប់លះរៀរនោះហោង។

២០.

រៀនមិនទាន់ចប់មួយសៀវភៅថាគេមិនដល់អញ
សីល៥នោះមិនទាន់គ្រប់ជ្រុងផងនូវតែថាមិនដល់អញ
សីលឧបោសថនោះបាត់ៗឃើញៗ នៅតែថាគេមិនដល់អញ
មិនទាំងដែលបានសេចក្តីស្ងប់ចិត្តក្នុងសមថសូម្បីតែមួយ
ផ្ចាត់ក្រចកផង នៅតែថាគេមិនដល់អញ ហើយមិនដែល ឃើញច្បាស់នូវកិរិយាដែលកើតឡើងនិងកិរិយារលត់ទៅ របស់នាមនិងរូបសូម្បីតែមួយប៉ប្រិចភ្នែកផង នៅតែថាគេមិនដល់អញ អើហ្ន៎ គួរគួរអស្ចារ្យណាស់តើអារឿងដែលថាគេមិនដល់អញនេះវាមានព្រំដែនត្រឹមណាទៅ ? ។

២១.

ស៊ីម្ទូរទឹកប្រហុកគង់គេលាន់មាត់ឆ្ងាញ់
ស្តាប់ធម៌នោះមិញមិនឮឆ្ងាញ់សោះ
ចាយលុយធ្វើទានមានតែភ័យខ្លាចសោះ
ត្រង់កន្លែងនេះកន្លែងនោះអស់ប៉ុន្មានក៏អស់ទៅ។

២២.

រឿងណាដែលត្រូវច្រើនតែនៅលើខ្ញុំ
ខុសតូចខុសធំច្រើនតែនៅលើគេ
កំហុសខ្លួនឯងថ្លៃមិនសូវចេញទេ
បើកំហុសរបស់គេឃើញផងឮផង

២៣.

បើចង់បានគ្រាន់បង្អន់រឿងអួត បើមិនចង់បានឆ្កួតចម្រើនសតិ
ចង់ចៀសអបាយរម្លាយទិដ្ឋិ កិលេសប៉ប្រិកុំបឿងឋានសួគ៌។

២៤.
គេឯណោះធ្វើអាក្រក់យើងឯនេះខឹង
តើទាំងពីរអ្នកហ្នឹងអ្នកណាគ្រាន់បើជាងអ្នកណា ?

## អំពីទោសរបស់កាម

## កំណាព្យពាក្យប្រាំពីរ

នាមដើមខ្ញុំឈ្មោះអក្សរ "ក"    អា ប្រកប ន នៅខាងចុង
រៀបរៀងធម៌នេះទុកបំរុង    ពួកជននៅក្នុងព្រះសាសនា
គ្រាន់បានអានមើលបានចេះដឹង    ត្រិះរិះរំពឹងពិចារណា
នូវទោសកាមគុណធ្ងន់ក្រៃណា    តាមដោយឧបមាមាន១០យ៉ាង
ចាប់ផ្ដើមនិពន្ធនៅថ្ងៃពុធ    ខែ១១គត់ពេលព្រឹកព្រាង
នាឋានទៀបវ៉នកោះកសាង    បានខាងនាថ្ងៃទី២៨។
ថ្ងៃ៩កើតខែមិគ្គសិរ    មមែជាឆ្នាំមានសេរី
ចុង៧៩ស្ទួនពិសី    កវីចាត់ចែងថ្លែងអត្ថា។
កាមមានរសផ្អែមដូចទឹកឃ្មុំ    បៀមបៅអារម្មណ៍ប្រាប្រការ
រូបសម្លេងក្លិននិរសា    មានផោដ្ឋព្វាគម្រប់ប្រាំ។

កំសាន្តហិចហក់ក្នុងភ្នក់កម្ម    រាល់ថ្ងៃខែឆ្នាំពុំមានល្ហែ
កាមនាំរីករាយនៅក្នុងលោក    ធ្លាក់ចិត្តជាប់ជាក់ដោយក្ដីស្នេហ៍។
កាមនេះតែងតែនាំបំភ័ន្ត    ទោះទុក្ខខ្លាន់ៗគង់មិនណាយ
គេតែងនាំចិត្តឲ្យរីករាយ    វេចស្លាយអារម្មណ៍ខាងឥដ្ឋា។
ប៉ុន្ដែបើស្ដីពីរឿងទោស    កំហុសឆ្លុះចេញឥតគណនា
គ្រប់ខ្យល់ចេញចូលគ្មានលោះគ្រា    ទើបលោកឧបមា១០សុទ្ធសឹង។
១អដ្ឋិកង្កលោហមា    កាមប្រហែលគ្មានឹងរាងឆ្អឹង
ជនណានៃបនិត្យពិតភ្នែកស្លឹង    ជញ្ជឹងជញ្ជប់ទឹកមាត់ឯង។
បានសេចក្ដីថាការស្វែងកាម    រហេមរហាមសែនចំបែង
ទុក្ខព្រួយកាយចិត្តឥតបើថ្លែង    ក្រៃលែងក្រៀមក្រោះគ្រឿងសោកសៅ
ដូចសត្វសុនខអង្កៀមឆ្អឹង    ទោះបីខំប្រឹងយ៉ាងណាទៅ
គ្មានបានពេញពោះរសជាតិជៅ    ប្រឹងទៅបានត្រឹមនឿយអាត្មា។

ឆ្លងដល់ទីពីរនិងរិះរេ    គឺមំសបេសូបមា
ទោសកាមដូចខ្លែងពាំមំសា    ឱរាតានតឹងសឹងភិតភ័យ។
ដូចជនអ្នកមានកូនប្រពន្ធ    ស្វាមីទ្រព្យធនគោក្របី

ក្នុងទ្រូងរែងទុក្ខទាំងយប់ថ្ងៃ ក្រែងជនដទៃលែលួចឆក់។
ណាមួយលំបាកព្រួយរក្សា ណាមួយចិន្តាកករល្អក់
ក្នុងទ្រូងខ្មេចខ្មាំដូចដំគក់ ណាដេកមិនលក់ព្រោះកង្វល់។

ទីបីតិន្នុគ្គោបមា ថាដូចគប់ភ្លើងកាន់ច្រាស់ខ្យល់
ដំបៅដួងចិត្តពិតអំពល់ ក្រវាយក្រវល់ព្រោះសោកស្តាយ។
ស្តាយមួយព្រោះព្រាត់ប្តីប្រពន្ធ សង្សារទ្រព្យធនឬព្រាត់ម្តាយ
ព្រាត់កូនសំឡាញ់ព្រោះទៅឆ្ងាយ ខ្វាត់ខ្វាយសម្បត្តិទ្រព្យនានា។
ព្រាត់សក្តិព្រាត់យសឈ្មោះធ្លាប់ល្បី ព្រាត់ខុសសេរីឬគ្រឹះហា
ត្រកូលពូជពង្សមិត្តទាសា ក្លាយជាក្តៅផ្សាឆេះខ្លួនយើង។

អង្គារកាសូបមា ទីបួនដូចជារងើបភ្លើង
ពេញក្នុងរណ្តៅច្រាសឆ្អៅឡើង ព្រោះកាមជាគ្រឿងសែនក្តៅធំ
ឥតមានលោះលាត្រាប្រណី រាល់រូបប្រុសស្រីដូចបូសកុម
សំរក់ទឹកភ្នែកសំរែកយំ ដូចដុំសិលាមហាធ្ងន់ក្រៃ។
ក្តៅមួយព្រោះចង់មិនដូចចិត្ត ក្តៅមួយព្រោះគិតនឹកអាល័យ
ក្តៅមួយព្រោះព្រាត់ឥតសង្ស័យ ចិន្តាដួងចៃឥតបីស្ងប់។

ប្រាំសុបិណគោបមា កាមនេះលោកថាដូចយល់សប្តិ
ជនណានៃបនិត្យពិតពុំស្កប់ ទោះច្រើនលើសលប់ឥតខ្លឹមសារ។
ស្រមើស្រមៃដូចស្រមោល ម្តងចេញម្តងចូលម្តងសោភា
ម្តងសើចម្តងយំដូរវេនគ្នា ម្តងខឹងម្តងជាម្តងគួរគាប់។
ម្តងណាហាក់ដូចជាស្រឡាញ់ ម្តងទោម្នេញពេញហៅស្ញប់
ស្រពិចស្រពិលស្រពោនអាប់ គ្មានក្តីខ្ជួនខ្ជាប់សឹងប្រួលប្រែ។
ឯយាចិតគោបមា ទីប្រាំមួយថាដូចខ្ចីគេ
ប្រើប្រាស់ភ័យស្លន់បន្ទន់រេ ព្រោះថាម្ចាស់គេនឹងតឹងទារ។
រីសង្ខារធម៌ផងទាំងឡាយ តែងតែឃ្លាតក្លាយចាស់គ្រាំគ្រា
ផ្ទុយនឹងបំណងសត្វនានា ទើបលោកប្រៀបថារបស់ខ្ចី។
ព្រោះថាសត្វលោកគ្មានកម្មសិទ្ធិ លើកាយជីវិតទាំងប្រុសស្រី
មច្ចុតឹងទារនារាល់ថ្ងៃ ឥតបីរេរាប្រកែកបាន។

ប្រាំពីររុក្ខផលោបមា ដូចផ្លែរុក្ខាគេរាប់អាន

ដុះនៅលើដីព្រៃព្រឹក្សឋាន គេតែងបៀតបៀនឥតប្រណី។
ជួនត្រូវដំបងជួនត្រូវទំពក់ ខ្ទេចខ្ទាំរីរក់កាប់កាច់រំរែ
វិនាសមែកដើមស្លឹកទុំខ្ចី ព្រោះអ្វីព្រោះតែខ្លួនមានផ្លែ។
រឿងរ៉ាវរបស់កូនឯណោះសោះ ម្ដេចក៏វាឆេះទ្រូងពុកម៉ែ
រឿងរ៉ាវលោកប្ដីឯណោះទេ ម្ដេចអាកូនគេមិនបានគេង។

ប្រាំបីសប្បិសូលោបមា កាមនេះលោកថាដូចលំពែង
ដែលមានមុខស្រួចដ៏ក្រៃលែង ហើយតែងបៀតបៀនមុតជាប់នៅ
មុតហើយមិនងាយនឹងដកបាន ធ្លុះចិត្តសន្ដានពេញហៅជ្រៅ
ប្រកបដោយពឹសសែនផ្សាក្ដៅ ដំបៅផ្លូវចិត្តមិនងាយជា។
លំពែងមានងៀងទៀងជាតឹង តែដកមិនដឹងអន្ទះសា
ក្រហាយក្រហល់ខ្វល់តក្កមា ជិះជាន់ផ្ដន្ទាគ្មានគ្រាភ្លេច។

ប្រាំបួនអសិសូនោបមា លោកថាដូចជ្រុញចិញ្ច្រាំសាច់
សម្រេចទៅដោយមុខកាំបិត ដូចកាមនាំចិត្តរងអារម្មណ៍
រូបសំលេងក្លិននិងរសា មានផោដ្ឋព្វាជាគម្រប់ប្រាំ។

វានាំឆន្ទរាគរាលដាលជាំ កាប់សាច់ចិញ្ច្រាំដួងហឫទ័យ
ផ្ជួនហើយផ្ជួនទៀតឆ្លៀតបន្ថែម មានជូរមានផ្អែមមានហើរប្រៃ
ចេញសោកនាដកម្មប្រចាំថ្ងៃ ក្នុងភពលោកិយពេញហៅគ្រោះ

ដប់សប្បសិរោបមា ទីចប់លោកថាដូចក្បាលពស់
តែមានខាំហើយមិនងាយរស់ ព្រោះពស់មានពិសដ៏ខ្លាំងខ្លា។
កាមតែងបៀតបៀនកាមតែងប្លន់ វាដាក់ទារុណសត្វលោកា
ឲ្យសោកសង្រេងថ្លែងចរចា ដុតរោសឱរាផ្សាក្រហល់។
តានតឹងតោកយ៉ាកលំបាកយ៉ាងប់ ចុកចាប់អួរអាប់ដូចថ្នាំពុល
ពឹសកាមរែងខ្លាំងគ្មានអ្វីដល់ អកុសលដេរដាស់ក្រាស់ក្រៃណា
សប្បុរសទាំងឡាយចូរិៈគត ត្រិះរិះពិនិត្យដោយប្រាជ្ញា
នូវទោសកាមគុណដប់ប្រការ ដូចបានពណ៌នាមកនេះឯង។
ទោសកាមតមាមចែងមិនទាន់ចប់ មិនមែនត្រឹមដប់ដូចសំដែង
តាមពុទ្ធតម្រាស់ត្រាស់ក្រៃលែង កវីសូមតែងថ្លែងបន្ត។
ជនខ្លះធ្វើស្រែធ្វើចំការ ខ្លះណាក៏ជាពាណិជ្ជករ
ខ្លះទៀតរៀនលេខរៀនអក្សរ ខ្លះជាទាសករអាជីប។

ខ្លះចិញ្ចឹមគោចិញ្ចឹមក្របី រឿងកាមនោះនៃធ្ងន់ដុនដាប
ខ្លះធ្វើអ្នកហ៊ានគ្មានគិតបាប ព្រោះកាមត្បុតកៀបគ្រប់ចលនា។
ពេលដែលចេញស្វែងរកសម្បត្តិ ជាទុក្ខពេកក្តាត់ព្រោះរងារ
និងព្រោះកំដៅព្រះសូរិយា ទុក្ខមួយស្តីថាព្រោះស្រេកឃ្លាន
ទុក្ខព្រោះសម្ផស្សរបោមមូស សត្វក្អែបខ្ទួយពស់តាមបៀតបៀន
នេះហើយទោសកាមតាមឈ្លានពាន ដែលអាចធ្វើបានក្នុងបច្ចុប្បន្ន
ជួនកាលជួញខាតសែនខកចិត្ត ជួនចំណេញពិតត្រូវចោរប្លន់
ជួនត្រូវអ្នកធំអូសរឹបជាន់ ជួនត្រូវទឹកជនលិចអន្តរាយ។
ជួនត្រូវភ្លើងឆេះកណ្តៀរស៊ី កណ្តុរឃាឃីមាន់កកាយ
សត្រូវនៃទ្រព្យហួសបរិយាយ នេះហើយលោកថាទោសកាមពិត
ជួនកាលចេញជួញមិនចំណេញ ទុក្ខមនោទោម្នេញពេញភ័យភិត
ចង្អៀតចង្អល់អម្ពល់ចិត្ត រិៈគិតខ្វល់ខ្វាយព្រួយរក្សា។
កាមនាំឲ្យម្តាយឈ្លោះនឹងកូន នាំបងឈ្លោះប្អូនមីងឈ្លោះមា
ទាស់ទែងរាជានិងរាជា កើតកម្មវេរាពៀរយូរលង់។
សត្វលោកដែលត្រូវកាមដឹកនាំ សាងទុក្ខរិតកម្មពិតភក់ផុង
វង្វេងវិលវល់សែនវៀចវង់ លិចក្នុងអន្លង់ទុក្ខទោសា។

កាមនាំសម្លាប់នាំលួចប្លន់ លួចកូនប្រពន្ធពោលមុសា
នាំសេពមេរ័យនិងសុរា សាងកម្មពាលាច្រើនឥតបី។
រីកាមមានទោសច្រើនអនេក ក្រៃធ្ងន់ពន់ពេកហួសឧបមេយ្យ
ធ្ងន់លើសអម្រែកសុមេរ័យ ភពបីគ្មានអ្វីក្តៅលើសកាម។
កាមនាំឲ្យសត្វវិបត្តិចិត្ត កាមនាំវិបត្តិដិតដក់ដាម
ភ្លេចពាក្យប្រដៅក៏ព្រោះតាម លែងប្រតិបត្តិតាមព្រោះកាមដែរ។
កាមនាំឲ្យអាប់អន់កេរ្តិ៍ឈ្មោះ កាមនាំថយយសនាំវៀចវេរ
កាមនាំឲ្យភ្លេចគុណឪម៉ែ ដូចដែលនិទានរឿងមោគ្គល្លាន។
កាមនីវរណៈគ្រឿងរារាំង កាមផ្ទាំងងងឹតបាំងនិព្វាន
កាមបាំងភពព្រហ្មបាំងសួគ៌ឋាន កាមអាចនាំប្រាណដល់អវចី។
ដូចនិព្វាននៃនន្ទមាណព បានរួមប្រសព្វព្រះថេរី
ជាសាវិកាព្រះជិនស្រី ខ្លួនដល់អវិចីប្រាកដពិត។
ទោសកាមដូចស្តែងដោយឧបមា មានដល់ប្រការជាកំរិត
តែទោសក្រៅនេះអនេកពិត តែងបៀតបៀនចិត្តឥតមេត្តា
កាមជាបូសរោគកាមជាសរ កាមនេះជាគរជាឈើផ្សា
កាមកើតម្តងៗហិនិកុសលា កាមនាំចិន្តាឲ្យពុះក្តៅ

កាមគុណជាគ្រឿងជាប់ជំពាក់ ជាសញ្ញោជនៈស្មូពូជផៅ
កាមជាអនុស័យដេកត្រាំនៅ កាមនេះជាផៅនៃពួកមារ។
កាមតែងឃ្លានពានរុរានហួស កាមនាំអ្នកបួសលាសិក្ខា
កាមនាំឧបាសកឧបាសិកា តិរច្ឆានកថានាថ្ងៃសីល។
កាមនាំឲ្យឈប់កាន់សីលប្រាំ កាមនាំធ្វើកម្មកបមន្ទិល
កាមនាំកាយចិត្តខិតអង្ក្រិល បង្ហិលមុខសត្វចំអបាយ។
កាមនាំប្រឆាំងនឹងព្រះពុទ្ធ ប្រទូស្តតយុទ្ធធម៌ទាំងឡាយ
កាមនាំកំណាញ់ទឹកកំណាញ់បាយ កាមណាំឲ្យឆ្ងាយពីសាសនា។
យោនរោរីនរៈទោះប្រុសស្រី ចូរខំលកលៃពិចារណា
នូវទោសកាមគុណដោយបញ្ញា ដូចខ្ញុំពណ៌នាមកនេះឯង។
អហំ រីខ្ញុំសូមបន្ទន់ ឱនកាយអភិវន្តគោរពក្រែង
ចំពោះអ្នកស្តាប់គ្រប់កន្លែង សូមថ្លែងអំណរដ៏ថ្លាថ្លៃ។
រីផលដែលខ្ញុំបានរិៈគិត ត្រិះរិៈពិនិត្យក្នុងហឫទ័យ
ខ្ញុំសូមបង្គំឱនសិរិសី លើកដៃប្រណម្យសូមប្រាថ្នា។
ទោសកាមទាំងឡាយសូមឆ្ងាយបង់ យល់ល្អត្រូវត្រង់ដោយបញ្ញា
ឃើញទោសកាមគុណដូចសច្ចា កុំបីយល់ថាទោសជាគុណ។

សូមបានក្រេបផឹកទឹកអំរិត ត្រជាក់ពេកពិតប្រសើរលន់
ភពបីវែងទុក្ខក្រៃពេកពន់ សូមបុណ្យនាំចេញដូចប្រាថ្នា។
បើមិនទាន់ដល់អមតៈឋាន នោះខ្ញុំសូមមានចិត្តចេតនា
ប្រោះព្រំដោយក្លិននៃកុសលា ដូចក្លិនបុប្ផាពិដោរឈ្ងប់។
បើខ្ញុំនៅត្រាច់អន្ទោលទៅ គឺនៅមិនទាន់ប្រាសចាកភព
នោះខ្ញុំសូមបានរួមប្រសព្វ អំពីប្រភពអ្នកមានសីល។
សូមមានវាចាចាសុភាសិត ផ្អែមដូចអំរិតប្រាសមន្ទិល
គ្រប់ជាតិខ្ញុំសូមជាប់នៅសីល ជាសីលដូរជីវិតពិតឥតស្តាយ។
ដោយផលធម្មទានជាកំណត់ សច្ចាគ្រប់បទកុំបីណាយ
សូមស្ថិតនៅនិត្យជិតចិត្តកាយ កុំបីក្លាយជាការដទៃ។
រីផលធម្មទានមានឥទ្ធិពល សូមបុណ្យបានដល់បុព្វការី
ឧបជ្ឈាយាចារ្យបងប្រុសស្រី ដែលជាប់និស្ស័យគ្រប់ជនជាតិ។
មួយអន្លើដោយសត្វគ្រប់ៗឋាន ព្រមទាំងគ្រប់ប្រាណសន្តានញាតិ
ដែលជាប់និស្ស័យជាទាយាទ ដែលឃ្លាតព្រោះចាញ់មច្ចុមារ។
សូមអញ្ជើញលោកមកទទួលផល ធម្មទានកុសលដ៏ថ្លៃថ្លា
ក្តីសុខចម្រើនគ្រប់ប្រការ ស្រេចតាមប្រាថ្នានៃលោកចុះ។

២៦.
ជនសំឡឹងប្រឹងសម្លក់អ្នកដទៃ     គយរំពៃទោសតូចធំផ្តុំដាក់គេ
តាមសាសនាច្បាប់លោកថាមិនល្អទេ គិតរិះរេគួរកែប្រែបែររលះបង់

២៧.
ជីវិតអ្នកក្រដូចជាជុំថ្មគ្រួស     ជីវិតអ្នកបួសដូចបក្សីក្រៅអន្ទាក់
ជីវិតអន្ធពាលដូចម្រឹគក្នុងផ្ទាក់ ជីវិតប្រាជ្ញជាក់ដូចកែវមណីជោតិ។

២៨.
ជីវិតអ្នកមានដូចពានវង្វាន់     ជីវិតខ្ញុំតណ្ហាដូចស្វាជាប់ជ័រ
ជីវិតអ្នកខ្លៅដូចសត្រូវច្បាមក     ជីវិតទ្រង់ធម៌ដូចភ្នក់អត់ភ្លើង។

២៩.
ទោសៈហ្នឹងឯងនាំឲ្យល្ងង់     លោភៈហ្នឹងឯងនាំឲ្យងងឹត
មោហៈហ្នឹងឯងនាំវិបរិត្ត     ចេះហើយប្រមាទពិតផ្តាស់ទទេ។

៣០.
បើស្បែកនៅផុយកុំប្រថុយមុខកាំបិត  ចិត្តនៅក្តៅពិតកុំជិតអ្នកជេរ
គ្មានមិត្តសប្បុរសស៊ូនៅទំនេរ     បើចិត្តនៅស្នេហ៍កុំក្បែរស្រីមុំ។

៣១.
អ្នកក្រជិះកង់គង់មានគេថាណាស់
អ្នកមានជិះឡានចាស់មានថ្វីនិងគ្រាន់បើ
យរាវាសធ្វើទានគង់មានគេសរសើរ
សីលខ្ពស់តែស្មើរមិនគ្រាន់បើឡើយ។

៣២.
រឿងតម្រេកជាតម្រេះគួរតម្រឹម     ពុទ្ធតម្រាស់គួរញញឹមយកតម្រាប់
រឿងតម្រាជាតម្រងចង់ជាច្បាប់     ខុសប្រញាប់ឆាប់តម្រង់តម្រូវ។

៣៣.
បើក្រសូមអង្វរកុំជំពាក់     បើស្មោះពិតស្ម័គ្រកុំទារថ្លៃ

បើអាណិតសូមចិត្តកុំខឹងអី ឲ្យចំណីសូមកុំលៃលាយថ្នាំពិស។

៣៤.

ជនណាបរិសុទ្ធដោយខ្លួនឯង ប្រឹងប្រែដឹកនាំអ្នកដទៃ
សង្គ្រោះដឹងគុណអចិន្ត្រៃយ៍ ជននោះលោកស្ដីថាបណ្ឌិត។

៣៥.

ជនអត់វិជ្ជាដូចនេត្រាអត់ប្រស្រី ជនអត់សេរីដូចចាប៊ីអត់ដង

៣៦.

បើគិតឃើញស្អាត សូមកុំភ្លេចរឿងខាត បើមើលឃើញស្អាត
សូមកុំភ្លេចរឿងស្អប់ បើឃើញកំហុស សូមកុំភ្លេចគុណគាប់
ធម្មតាថ្ងៃនិងយប់ជាគូគ្នា។

៣៧.

ទឹកសមុទ្ររាប់ប៉ោតតោនមិនអស់ ច្រើនម្លោះតែទាស់មានរសប្រៃ
ជនណាឃ្លានស្រេកដូចម្ដេចក្ដី មិនអាចអាស្រ័យទឹកនោះបាន។
ឧបមានដូចជាចិត្តកំណាញ់ មានទ្រព្យពោរពេញគេហដ្ឋាន
វិជ្ជាយសសក្ដិថ្នាក់ថ្កើងថ្កាន អ្នកផងមិនបានសុខដោយសារ។
ទឹកសាបសូម្បីមួយទូកដៃ គង់គួរគប្បីដល់ជនា
ពិសាក្រេបផឹករសគង្គា កម្ចាត់វេទនាជាសុខសាន្ត។
ឧបមាដូចជនមិនកំណាញ់ ទ្រព្យតិចម្ដេចមិញគង់ចែកទាន
ទោះយសសក្ដិទាបភាពស្មើប្រាណ អ្នកផងជើងឆើតអើតខាងស្អប់
រាគៈជើងឯកប៉ែកខាងកាប់ មោហៈជើងជាប់លេខខាងល្ងង់។
យោនរោ រីនរៈអ្នកចូរប្រឹង កិលេសអស់ហ្នឹងនាំលិចលង់
គេទៅស្ថានសួគ៌ឲ្យរហង់ អ្នកផុងអបាយភូមិសមដែរឬ?។

៣៩.

ឬស្សីអើយឬស្សី ដុះនៅលើដី ចេញដៃសាងញ៉ាង
មួយឆ្នាំពីរឆ្នាំ ទំពាំងច្រូងប្រាង ដូចម៉ែមីនាង
តើរាងទេខ្ញុំ? ។

៤០.

ចំណែកនាងចេក គេទូលគេរែក គេកាប់បន្ទុំ
ផ្អែមគ្រាន់បើដែរ រាងផ្លែក៏សម តែទាស់មាសមុំ
ជោររទ្បេះក ។

៤១.

ម្ដែសាមសិបរៀលបង់ទៅចុះ កុំតែបង់ឈ្មោះយសសេរី
លុយកាក់ប្រាក់មាសបង់វាហី បង់សេរីចាត់ជាចង្រៃធំ។

៤២.

ឯណាខ្ទិះដូងគេឈោងដៃខ្វប់ កាកៗគោរពជូនមិត្តពិសារ
ពាក្យសែនពិរោះលាយសម្រស់ភក្ត្រា តែនេះចាត់ជាអការទូរមិត្ត
ឯណាក្បាលទឹកគេផឹកធ្មេចភ្នែក អំពៅស្ករចេកស៊ីពេលងងឹត
សំណាកកាកឃុំប្រជុំជួបមិត្ត នេះចូរដឹងពិតទូរមិត្តដូចគ្នា។

៤៣.

រីវរៈនិងពស់វែកតិចថាបានដេកថ្ងូ ឃើញក្បាលខ្ញុំកោរកុំទានឲ្យពិន្ទុ

៤៤.

បើស្មៀមគួរស្មៀមដោយក្ដីស្ងប់ តែស្មៀមដោយស្អប់ប្រាជ្ញមិនស្មើច

៤៥.

ស្រុកនរកមានរណាជួយនរណា ម្នាក់ៗក្ដៅផ្សាជាអនន្ត
ក្ដីទុក្ខរីតរួតត្រួតខ្នាន់ៗ ឥតមានស្រាកស្រន់មួយវេលា។
ស្រុកប្រេតលំបាកព្រោះអត់ឃ្លាន យូរៗទើបបានបរិភោគក្ដា
ដោយផលនៃទានដ៏ថ្លៃថ្លា ដែលញាតិករុណាឧទ្ទិសឲ្យ។
តិរច្ឆានព្រួយប្រាណលំបាករស់ ទោះបានដាក់ពោះខ្លះក៏ដោយ
ក្ដីសុខតែងមានយ៉ាងខ្សត់ខ្សោយ ព្រោះផលប្រគល់ឲ្យទៅតាមកម្ម។
ស្រុកមនុស្សស៊ីផុះរស់មិនយូរ គន់គូរកម្របានមួយរយឆ្នាំ
ចាស់ឈឺស្លាប់មានជាប្រចាំ បុញ្ញកម្មគួរស្អាងឲ្យបានស្អាត។
ស្រុកទេពសម្បូរបែបបទប៉ែកកាមគុណ ទេពណាលង់ស៊ុនគង់ភ្លាត់ផ្លាត
ទេពណាមានបញ្ញាមិនប្រមាទ ទេពនោះហៅស្អាតជាតិឧត្ដម។
ស្រុកធំជាជំរុំអ្នកបុណ្យខ្ពស់ មិនបាច់ស៊ីផុះរស់សុខុម
កើតដោយឈានចិត្តដែលខិតខំ តែគង់ជាខ្ញុំនៃតណ្ហា។
និព្វានតែងមានជាប្រាកដ កំណត់ត្រង់ចប់នូវបញ្ហា

កិលេសមិនឆេះក្នុងទីណា ទីនោះហៅថាព្រះនិព្វាន។
នរកប្រេតតិរច្ឆាននិងឋានមនុស្ស ទេវតាព្រហ្មខ្ពស់និងនិព្វាន
ដូចដែលរាប់មកទាំងប៉ុន្មាន តើអ្នកបានឋានណាដែរ។

៤៦.
អារឿងគេជេរវាមានទៅបាបអីខ្ញុំ តែរឿងដែលធំកុំតែខ្ញុំជេរគេ
៤៧.
អារឿងគេថាវាមានទៅខាតអីខ្ញុំ តែរឿងដែលធំកុំតែខ្ញុំថាគេ

៤៨.
រឿងខានស្តាប់ធម៌ជារឿងធំ សព្វបើគ្រាន់តែអារឿងខានស៊ីនំ
ចាំបាច់នៅផ្ទះអន្ទះសា ។

៤៩.
បុគ្គលទទួលទេយ្យធម៌អំពីជនដទៃ
ទោះបីតិចក្តីច្រើនក្តីមិនដែលបានបុណ្យឡើយ

តែបើបុគ្គលប្រកបដោយសទ្ធានិបញ្ញាហើយ
បានឲ្យទេយ្យធម៌ទៅជនដទៃ។
ទោះបីតិចតួចក៏ដោយរមែងបានបុណ្យជាប្រាកដ
ចាំបាច់ពោលទៅថ្វីដល់ទៅ
របស់ច្រើនដូច្នេះការឲ្យពិតជាប្រសើរជាងការទទួល
តើអ្នកជាអ្នកត្រេកអរក្នុងការទទួលឬក្នុងការឲ្យ ? ។

៥០.
ចង្រៃអ្វីមិនស្មើនឹងក្តីល្ងង់ លង់អ្វីមិនស្មើនឹងសង្សារ
អាវុធអ្វីមិនស្មើនឹងបញ្ញា កម្រអ្វីមិនស្មើនឹងអត់បុណ្យ។

៥១.
បានអ្វីមិនស្មើនឹងបានចេះ ជំនិះអ្វីមិនស្មើនឹងវាស្នា
ចាញ់អ្វីមិនស្មើនឹងអត្តា រូបឱរាអ្វីមិនស្មើនឹងផលបុណ្យ។

៥២.

គ្រោះអ្វីមិនស្មើនឹងចិត្តបាប    ដាបអ្វីមិនស្មើនឹងអស់ទុន
អន្លង់អ្វីមិនស្មើនឹងកាមគុណ    កុនអ្វីមិនស្មើនឹងក្ដីប្រមាទ។

៥៣.

ស្អិតអ្វីមិនស្មើនឹងរឿងចង់    ត្រង់អ្វីមិនស្មើនឹងបន្ទាត់ខ្នាត
មនុស្សល្អពិតក្រជាងមនុស្សស្អាត    មនុស្សឆ្លាតមានតិចជាងមនុស្សល្ងង់

៥៤.

សុញអ្វីមិនស្មើសុញគំនិត    វិសុទ្ធិអ្វីមិនស្មើចិត្តផូរផង់
ជួបអ្វីមិនស្មើជួបពុទ្ធអង្គ    វិលវល់អ្វីមិនស្មើនឹងសង្សារ។

៥៥.

បីសាចអ្វីមិនស្មើនឹងឧបាទាន    ភ្លើងចង្ក្រានមិនស្មើនឹងតារា
ទម្ងន់អ្វីមិនស្មើនឹងខន្ធា    មាគ៌ាអ្វីមិនស្មើនឹងវិសុទ្ធិ។

៥៦.

ពិរោះអ្វីមិនស្មើនឹងព្រះធម៌ថ្លៃ    តម្លៃអ្វីមិនស្មើនឹងកុសលធម៌
ប្រពន្ធស្អាតមិនស្មើនឹងប្រពន្ធល្អ    ក្រអ្វីមិនស្មើនឹងរបស់ដែលអត់

៥៧.

ដីថ្មសំណដែកដប់គីឡូ    ជនមិនឆ្កួតគេមិនដូរមាសតំឡើង
កែវកងន្ទួនល្អងស្រស់ច្រលឹង    មុនីដឹងគេមិនប្រឹងដូរធម្មា។

៥៨.

សត្រូវអ្វីមិនស្មើនឹងកិលេស    ឆ្អាបឆ្អេះមិនស្មើនឹងលុបគុណ
ចំណងដែកមិនស្មើកូនប្រពន្ធ    ធន់អ្វីមិនស្មើនឹងកិលេសប្រើ។

៥៩.

សត្វស្វាស៊ីស្វាយមិនស្ដាយគ្រាប់    ត្មាតស៊ីសាកសពមិនជិនណាយ
ជនពាលមិនឆ្អែតបាបទាំងឡាយ    បណ្ឌិតមិនងាយឆ្អែតធម្មា ។

៦០.

ឯបង្គន់មាននរណាគេស្រឡាញ់ ទាស់តែចេញអាហារចាស់គេទេវ៉ា មនុស្សយើងមាននរណាគេត្រូវការ តែដោយសារគេប្រាថ្នាប្រយោជន៍តើ

៦១.
ឋានសួគ៌ក៏ដោយនិព្វានក៏ដោយ វាមានទៅលំបាកចាក់ស្មាន ដូចកន្ទុយលេខឯណា ការពិតនោះឲ្យតែយើងមានទុនមានសទ្ធាជាដើមហើយ អាចបើកចាក់បានដោយសេរី ។

៦២.
តាមសមាណវិន័យដូចសេដ្ឋីមានធន
បណ្ឌិតអត់ប្រពន្ធដូចព្រះច័ន្ទអត់ពពក។

៦៣.
ក្នុងបច្ចុប្បន្នជាតិនេះកាលបើយើងសង្កេតឃើញថា
ចិត្តរបស់យើងលោភៈមួយរលត់ទៅលោភៈមួយកើតឡើង ទោសៈមួយរលត់ទៅទោសៈមួយកើតឡើង ។ល។ កាលបើកិលេសតគ្នានឹងកិលេសដូច្នេះ តើបដិសន្ធិថ្មីដែលត្រូវបន្តវេនអំពីមរណសន្ធជវនទៅនោះ នឹងទៅជាបដិសន្ធិដ៏ឧត្តមម្តេចកើតទៅ លើកលែងតែអតីតកម្មដ៏យូរលង់ ចូលចួយធ្វើអន្តរាគមន៍តែប៉ុណ្ណោះ។

៦៤. ការធ្វើបាបអ្វីមួយបើទុកជាមិនមានមនុស្សណាម្នាក់គេមិនឃើញទេក៏គួរតែខ្មាស់អស់ពពួកទេវតាបើមិនខ្មាស់អ្នកណាក៏គួរតែខ្មាស់ខ្លួនឯង។

៦៥.
ឃ្លានអ្វីមិនស្មើនឹងឃ្លានចេះ ឆ្អែតវិសេសគឺឆ្អែតដោយបញ្ញា
តបគុណជាឫសនៃកុសលា តណ្ហាជាថៅកែស្រុកដាច់ដាប។

៦៦.
បើមិនទាន់ទល់គ្រប់សូមកុំទាររកចេះ
បើមិនទាន់អស់កិលេសសូមកុំទាររកនិព្វាន

បើមិនបានធ្វើបុណ្យសូមកុំទារសួគ៌ឋាន
បើលុយនោះគ្មានសូមកុំទារស៊ីឆ្ងាញ់។

៥៧.

ឧបមាដូចជាផ្ទាំងនៃខ្សែពានមួយ ដែលកំពុងវិលចូលទៅឲ្យសស្រឹបនៅក្នុងអណ្តាតភ្លើង នៅលើផ្ទាំងនៃខ្សែពាននោះ គេសង្កេតឃើញមនុស្សខ្លះកំពុងតែស៊ីដណ្តឹងគ្នាដើម្បីរៀបការខ្លះទៀតកំពុងតែឈ្លោះទាស់ទែងគ្នាដណ្តើមផុងលាមកខ្លះទៀតកំពុងតែព្រៀងនូវគំរោងការដើម្បីសាងវិទ្យា ឬក៏ភូមិគ្រឹះ ។ល។ ទាំងអស់នេះមានឧបមាដូចម្តេចមិញ នោះក៏មានឧបមាយ្យដូចជាផ្ទាំងនៃលោកនេះ ដែលកំពុងតែវិលទៅកាន់ការចាស់ឈឺស្លាប់និងសេចក្តីព្រាត់ប្រាស់ដូច្នេះដែរ រីឯសត្វទាំងឡាយដែលកំពុងតែវង្វេងឈ្លក់ដោយសេចក្តីអាល័យក៏មានន័យប្រៀបដូចជាពពួកមនុស្ស ដែលនៅលើខ្សែពាននោះឯង។

៦៨.

ច្រឹមច្រុមច្រឹមច្រុមតិចចូលជ្រុញ វាច្រានជម្រុញទម្លាក់ជ្រោះ

បើជ្រេរឆាប់ជ្រៅកុំឲ្យជ្រួស តែហួសតិចជ្រុលដល់ជ្រែងខ្នង។
ត្រេងត្រាងត្រិបត្រុបតិចជាប់ទ្រុង ត្រួតត្រាឲ្យត្រង់កុំត្រាំត្រង
បើត្រេតកុំទ្រាលដល់សៅហ្មង ត្រិះរិះកុំឆ្គងទើបត្រឹមត្រូវ
បើភ្លេចកុំភ្លើឲ្យដល់ភ្លាត់ បើផ្លាតកុំផ្លាំងឲ្យខុសត្រូវ
បើផ្លង់ស្អាតភ្លឹងនោះមាននៅ ប្រឹងទៅកុំផ្លោះក្រែងហួសផ្លែ។
បើខ្មាស់គួរខ្មាស់អស់ចិត្តខ្មៅ ភូមិខ្មោចកុំនៅនាំខូចខ្មែរ
មុខខ្មូតសម្បុរខ្មុកស្រណុកកែ កុំតែចិត្តខ្មាំងនាំក្មេងតាម។
បើក្តាប់កុំក្តាប់ដល់ក្តៅដៃ ជឿឲ្យដឹងក្តីកុំដូចក្តាម
បើក្តាប់កុំក្តួងដល់រហាម បើជោរកុំញ៉ាមតាមគេក្តក់។
បើមិនចេះប្រឹងរៀនកុំមិនចង់ កុំគិតថាល្ងង់ឬគំរក់
បើមិនចូលប្រឹងប្រមូលកុំដំអក់ តក់ៗទៅណាវាមិនចាំ។
បើស្តាប់កុំចើកដល់ខូចចិត្ត បើចង់កុំជិតក្រែងដានដាំ
បើចេះកុំចើកដល់គេជេរ រិះរេតម្លឹងជីឲ្យបានច្បាស់
ចាំងដឹងប្រុងជើងឲ្យរហ័ស ឆ្ងាញ់ណាស់កុំចូកឲ្យហួសចាន។
បើស្អប់កប់កុំទុកដល់ស្អែក ក្តៅស្អុះឲ្យរែកទឹកស្រោចប្រាណ
ស៊ីស្អំតិចស្អកខករំខាន ខ្លួនប្រាណត្រូវស្អាងទើបបានស្អាត។

៦៩.

បើសាកកុំស៊ុនឲ្យដល់ស៊យ	បើស៊ីកុំសោយឲ្យគេសើច
បើសេពកុំសាញពាក្យចចើក	បើស៊ុំកុំខើចដល់សៅហ្មង។
បើឆោតៗឲ្យគេអាណិត	សុចរិតកុំសាងបែបឆៅៗ
បើឆេវកុំឆេះដល់ពុះក្ដៅ	ចង់ស្ងប់រកផ្លូវត្រូវអប់រំ។
បើល្បីកុំល្បីឲ្យហួសល្បើក	បើល្បួតកុំចើកទៅទាំងល្ងុំ
បើល្បះរកល្បិចប្រមូលផ្ដុំ	រករបរវៀររបាំងកុំលេងល្បែង។
បើភ្លើឲ្យកុំដល់ដាប	ចង់ដឹងបុណ្យបាបឲ្យមានក្រែង
បើដេកកុំជ្រុលឲ្យហួសល្ហែង	បើស្លួចត្រូវកេងកុំឲ្យដាច់។

៧០.

មនុស្សដ៏ឧត្តមគេមិនទ្រាំធ្វើបាប អំពៅក្នុងឃ្នាបនៅតែមានរសផ្អែម

៧១.

ថ្នាំអត់ស្លឹកដូចម្រឹកអត់ព្រៃ មនុស្សអត់វិន័យដូចឫស្សីអត់ថ្នាំង

៧២.

ចង្ក្រានអត់ឆ្នាំងដូចត្រពាំងអត់ទឹក ជនច្រណែនវវឹកដូចគេផឹកថ្នាំពិស ។

៧៣.

អ្នកឈឺគ្មានគ្នាដូចរងារគ្មានភួយ ចង់ឲ្យគេជួយទាល់តែជួយខ្លួនឯង។

៧៤.

ឲ្យតែកាមនៅកៀកចេះតែគិតឃើញគុណ
កាលណាកាមដកទុនគុណដូចគេកាយកប់ ។

៧៥.

អ្នកមានស្មារតីដូចដំរីមានហ្ម អ្នកមានធម៌ល្អដូចជាផ្គរមានភ្លៀង

៧៦.

ជីវិតអ្នកក្រដូចសម្លអស់គ្រឿង បើចង់ខ្លួនថ្កើងកុំឆ្មើងលប់គុណ

៧៧.

ជីវិតអ្នកមានដូចស្ពានស្ពត៌ ចង់សាងអាត្មាកុំឆ្ងាយអ្នកប្រាជ្ញ

៧៨.

រឿងរបស់គេកុំផ្ទេរដាក់ខ្លួន ធម៌ល្អគួរក្សនឲ្យពេញចិន្តា ។

៧៩.

កុំសង្ឃឹមរឿងសង្ហារថាសំខាន់ តែភាន់ភាំងចាញ់សង្ខោកដុបសង្ស័រ
រឿងសង្ឃោកុំសង្ខេបសេពដោយល្អ រសព្រះធម៌ក្នុងគួរចែងចារអសង្ខេយ្យ

៨០.

ចាតុម្មតាវតឹក្នុងតែចាញ់យាមា  តស្សិតស្ពគ៌ាក្នុងតែចាញ់និម្មា
បរនិម្មិត្តក្នុងតែចាញ់ព្រហ្មឋាន  សង្សារសុខសាន្តគង់និព្វានស៊ីដាច់

៨១.

មានសទ្ធាគួរគាប់អត់ទ្រព្យធ្វើទាន មានផ្លូវព្រះនិព្វានគ្មានអ្នកបដិបត្ត

៨២.

ជនអត់សំពត់ដូចមនុស្សអត់សីល
បានជាគេនោះខ្ចីលព្រោះមិនខ្មាស់ក្តីលួង់។

៨៣.

អ្នកមានបាបមិត្តងងឹតជាងដប់រោច
បញ្ញាមុតស្រួចគង់តែរួចខ្លួនបាន ។

៨៤.

លត់ដំដែកថៃបគង់តែងាយជាពិត ការទូន្មានចិត្តមិនងាយសោះទេ
ដាំពូជលើថ្មពិតឆ្នាំងទំនេរ  សុខចិត្តខ្ញុំគេល្អជាងខ្ញុំតណ្ហា។

៨៥.

កុំស្តាប់ហួសឮ  កុំមើលហួសឃើញ
កុំតឹងមុនទាញ  កុំជំនាញមុនចេះ ។

៨៦.

តែរកស៊ីជុំច្បាស់ជាខ្ញុំបានខាត  វិស្ស័យអ្នកឆ្លាតគេរកស៊ីរាយ
ឯពាក្យថាជុំគឺផ្តុំចិត្តកាយ  ឯពាក្យថារាយនាមផ្សេងរូបផ្សេង។

៨៧.
រៀនធម៌ច្រើនណាស់ ខ្លួនរិតតែចាស់ប៉ះញើកៗ
បុណ្យរិតតែដាបបាបរិតតែបើក ចិត្តដើររវើកជាងក្ដាមសមុទ្រ

៨៨.
ទីណាមានផ្សែងកន្លែងនោះមានភ្លើង
ទីណាមានយើងទីនោះមានស្លាប់
ទីណាមានស្រឡាញ់ទីនោះមានស្អប់
ទីណាមានគាប់ទីនោះមានទាស់ ។

៨៩.
រឿងខានទៅស្ថានសួគ៌ រឿងខានទៅនិព្វានជារឿងធំ
សូម្បីគ្រាន់តែរឿងខានស៊ីនំ ចាំបាច់ទៅយំរិតទ្រូង ។

៩០.
រឿងខានបានបុណ្យជារឿងធំ
រឿងគ្រាន់តែជេរខ្ញុំវាមិនធ្លាក់នរកឯណាខ្ញុំនឹង ។

៩១.
រឿងសាងកុសលជារឿងធំ សព្វបើគ្រាន់តែរឿងស្រីមុំចាំបាច់ទៅសោកា

៩២.
ពៅអើយអំពៅ រសផ្អែមមាននៅ គេតែងរាប់អាន
កាលណារសផ្អែម ល្ហែមចេញចាកប្រាណ នោះគេសន្និដ្ឋាន
ទុកជាសំរាម ។

៩៣.
បុណ្យបូកនឹងបុណ្យកុំបីបាត់ បាបនោះគួរបិទកុំបីបើក
រឿងបានរឿងបង់គង់កំរើក រៀមច្បងគួរលើកបត់បូជា

៩៤.

រឿងរបស់ប្រពន្ធកុំធ្ងន់ជាងម៉ែ    រឿងរបស់គេកុំធ្ងន់ជាងខ្លួន
រឿងរបស់ឪត្រូវតែធ្ងន់ជាងកូន    បើស្រឡាញ់ខ្លួនកុំពួនធ្វើបាប

៩៥.

ពោតអើយនាងពោត    ឬកនាងរាងស្លូត    ម៉ូតនាងនិមល
សន្លឹករេរាំ    ប្រគុំតាមខ្យល់    ទាស់តែមានកល
ដាក់ស្នូលថែមស្មៀត ។

៩៦.

ចង់បានសរសើរកុំនិន្ទាគេ    មិនចង់បានជេរកុំជេរគេមុន
ចង់បានក្តីសុខសំរុកសាងបុណ្យ    បាបជាដើមទុននៃទោសគ្រោះថ្នាក់

៩៧.

នៃនាងក្រូចឆ្មា    នៅក្នុងបន្លា    កុំថារួចខ្លួន
ជូរឆ្នាស់ពីម៉ែ    ហូរហែដល់កូន    ទោះខំកែខ្លួន
បានត្រឹមង៉ាំង៉ូវ ។
ចំនែកនាងស្វាយ    ខ្ចីជូរពីម្តាយ    រហូតដល់ឪ
តែគេចេះកែ    ប្រែតាមរដូវ    ដល់ចាស់ទុំទៅ
ផ្អែមគួរគាប់ហោង។
ប៉េកនាងននោង    គ្រាខ្ចីដំបូង    តែមានអ្នកផង
រក្សាថ្នមថ្នាក់    មិនឲ្យមានឆ្គង    ដល់ចាស់ស្វិតទង
បានត្រឹមដុះឆ្នាំង ។

៩៨.

បើចង់មានកុំសាងប្លង់ក្រ    បើចង់ល្អកុំសាងប្លងអាក្រក់
បើចង់ត្រជាក់កុំសាងភ្លើងភ្នក់    មិនចង់លុយភក់ទៅកើតឋានសួគ៌

៩៩.

បើមានៗឲ្យគេអរ    បើក្រៗឲ្យគេចូលចិត្ត
បើឆោតៗឲ្យគេអាណិត    បើល្អិតកុំដូចអាចម៍ទីទុយ។

១០០.

បើស្មៀមៗឲ្យគេរីករាយ    បើនិយាយៗឲ្យគេចូលចិត្ត

បើរៀនៗដើម្បីសុចរិត បើប្រព្រឹត្តឲ្យចំលើសាច់បុណ្យ។

១០១.

នៃវើយអាគក កុំធ្វើត្រកៗ អាងទឹកត្រឡោក
បង្កងរាងខ្ពស់ រស់អាងស្រូវដោក ទំពាំងចុះថោក
ប្រយ័ត្នចូលឆ្នាំង ។
នៃនាងចង្រិត សូមអង្វរចិត្ត ខំប្រឹងទប់ប្រាំង
សម្លេងតិចៗ កុំធ្វើមាត់ខ្លាំង រដូវឡើងប្រាំង
ប្រយ័ត្នខ្លាញ់ជ្រូក ។

១០២.

នៃវើយកង្កែប មាត់រាងច្រវែប បែបរាងសង្ហា
ភ្លៀងធ្លាក់ដំបូង ចង្កោងឡូឡា ប្រយ័ត្នកង្វារ
ក្វារចេញពីរន្ធ ។
នៃនាងអំពិល បើនាងឯងខ្ជិល មិនសូវទុក្ខធ្ងន់
តែល្អែងចេញត្រួយ តិចព្រួយអាសន្ន ទទួលទោសទណ្ឌ

ជាមួយកង្កែប ។

១០៣.

ស្រ្តីអត់ធម៌ ដូមសម្លអត់ប្រៃ
បុរសអត់វិន័យ ដូចក្របីដាច់កន្លស។

១០៤.

បុរសអត់ធម៌ ដូចបបរដីខ្សាច់
ស្រ្តីសីលដាច់ ដូចប៊ិចអត់បណ្ដូល។

១០៥.

ប្រាជ្ញអត់ខន្តី ដូចដំរីអត់ភ្លុក
កិលេសដឹកមុខ ដូចអ្នកគុកជាប់ខ្នោះ ។

១០៦.

តាបសមិនសង្រួម ដូចខ្ទមអត់ដំបូល
ដូចជីស្លៀកហូល ដូចក្រោលអត់គោ ។

ព្យាបាលអត់ថ្នាំ　　ដូចដំណាំអត់ជី
មិនសង្រួមឥន្ទ្រីយ　　ដូចលីធុងភ្លើង ។

១០៧.
អ្នកសុំតែងតែទាស់ចិត្តអ្នកឲ្យ　　ការសុំហ្នឹងហើយនាំបែកមិត្ត
អ្នកសុំងាយអ្នកណាចង់ដើរជិត　　ជាតិបណ្ឌិតត្រូវគិតហើយទើបសុំ
អ្នកឲ្យម្ដេចឡើយគេចង់អស់　　មាសប្រាក់ទ្រព្យរបស់គេខំផ្ដុំ
អ្នកឲ្យតែងទាស់ចិត្តអ្នកសុំ　　រៀរតែវង្សបរមអង្គសម្មា ។

១០៩.
អ្នកខ្លៅធ្វើប្រាជ្ញដូចអ្នកខ្លាចធ្វើទាហាន
អ្នកក្រធ្វើមានដូចចង្ក្រានអត់អុស ។

១១០.
បើចង់ភ្លើងឆេះយកផ្លិតបក់　　មិនត្រូវដំអក់នាំភ្លេចដៃ
បើឆ្អិនឬពុះត្រូវសម្ងៃ　　លកលៃយកទឹកមកលត់ភ្លាម។

ដើម្បីរៀនរស់ឲ្យបានយូរ　　មិនត្រូវបន្ទូរក្ដីព្យាយាម
តែភ្លើភ្លេចភ្លឹកតែងរហាម　　តិចក្រវាតាមច្បាមក្បាលជាប់។
ត្រូវរៀនក្រមុនសឹមមានក្រោយ　　សន្សំញយៗទើបបានគ្រប់
តិចបូកនឹងច្រើនកើនប្រសព្វ　　ចុងចប់ក្រែងរួចពីគ្រោះក្រ ។

*កំណាព្យនេះរៀបរៀងឡើងដោយធម្មាចារ្យ* ***ឆឹម ភាន*** *កាលគាត់នៅរស់ឥឡូវបានធ្វើអនិច្ចកម្មហើយ សូមឧទ្ទិសកុសលនៃធម្មទាននេះចំពោះគាត់ព្រមទាំងញាតិ បើបានអនុមោទនាហើយសូមបានសេចក្ដីសុខចុះ ។*

## ប្រពន្ធ៧យ៉ាង

មួយសោតព្រះពុទ្ធ　　ទេស្នាចំហុត　　ថារីកភរិយា
មានប្រាំពីរស្មោះ　　ប្អូននោះចិត្តជា　　បីនោះមោហោ
　　ចិត្តខូចងាយដាយ។
ឯប្រពន្ធជា　　ឯកឈ្មោះមាតា　　ភរិយាដូចម្ដាយ
ឈឺឆ្អាលកូនខ្លួន　　រវែងសួនមិនណាយ　　មិននឹករសាយ
　　ចិត្តចាំអាណិត ។

កូនទុក្ខទោសម្ដេច ខ្សត់ក្រច្រើនតិច ខឹងខុសខូចចិត្ត
ព្រាត់ប្រាស់យូរលង់ ពុំបង់បែកចិត្ត គង់ចាំចិត្តគិត
ឈឺឆ្អាលកូនស្មោះ ។
ប្រពន្ធណាគាប់ ឈឺឆ្អាលប្ដីខ្ជាប់ ចិត្តចាំកាន់កោះ
ដូចម្ដាយស្រឡាញ់ កូនពេញពីពោះ ហៅប្រពន្ធនោះ
ថ្លៃឥតផ្ទឹមដល់ ។
ប្រពន្ធជាទ្វី ឈ្មោះហៅទាសី ភរិយាដូចកល់
ខ្ញុំនឹងអម្ចាស់ ប្រើណាស់ខ្វាយខ្វល់ អាចអត់ទប់ទល់
ទម្ងន់បម្រើ ។
មិនមានទំនេរ ទោះម្ចាស់វាយជេរ អត់ឱនសារពើ
តាមតែបង្គាប់ ប្រញាប់ចង់ធ្វើ ចិត្តពុំសើរើ
ចៀសវាងក្រោធា ។
ប្រពន្ធណាអត់ ឱនអង្គអំណត់ ខ្លាចប្ដីអាត្មា
ដូចខ្ញុំនឹងម្ចាស់ ខ្លាចណាស់ធានា ប្រពន្ធនោះជា
ប្រសើរសុខសួន្យ ។
ប្រពន្ធជាត្រី ឈ្មោះភគិនី ភរិយាដូចប្អូន
ស្រឡាញ់បងពិត លំអិតលំអូន ទទួលដំបូន្ម
មានមាត់ពាក្យបង ។
ផ្ដាច់ផ្ដួលតែមួយ នឹងចងជាត្រួយ ចិត្តចាំប៉ាបំណង
ពំនាក់ពំនឹង ពាក់ពឹងប៉ុនប៉ង តែនឹងអង្គបង
ឥតប៉ែទីទៃ ។
ប្រពន្ធណាចូល នឹងប្ដីមួយមូល ចិត្តជាប់អាល័យ
ដូចប្អូននឹងបង ចាំចងអាស្រ័យ ប្រពន្ធនោះថ្លៃ
មធ្យមពេកពិត ។
ប្រពន្ធចត្វា នោះហៅសាខា ភរិយាដូចមិត្រ
សំឡាញ់ស្រឡាញ់ អស់អញពេកពិត ស្មើខ្លួនស្មើចិត្ត
ស្ម័គ្រស្មោះចិន្ដា ។
បើមិនទៅបាត់ ស្ងប់ស្ងួតមុខមាត់ ទុក្ខទន់ទ័យា
ឃើញមុខមកបាន ចិត្តក្សាន្តសោះសា ស្រស់ស្រួលភក្ត្រា
និរទុក្ខសោកសៅ ។
ប្រពន្ធណាចិត្ត ស្រឡាញ់ប្ដីពិត គ្មានក្នុងគ្មានក្រៅ
ដូចមិត្តនឹងមិត្ត ចងចិត្តជាប់នៅ ប្រពន្ធនោះហៅ

ឧត្តមក្រមាន ។
សម្ដែងភរិយា ទាំងបួនសឹងជា ក្រស្រីធ្វើបាន
បើស្រីណាគិត ផ្ចង់ចិត្តសន្ដាន ស្រឡាញ់ប្ដីប្រាណ
ដូចធម៌ទេស្នា ។
លោកថាស្រីនោះ ឮកេរ្ដិ៍ពីរោះ ទូទៅនានា
បើអស់ជីវិត ទៅឋិតសួគ៌ា ចៀសចាកចតុរា
បាយបាបទុក្ខភ័យ ។
ប្រពន្ធពុំជា ឈ្មោះវធកា- ភរិយាដូចនៃ
សត្រូវចាំចង ទោសផងសព្វថ្ងៃ ប្រពន្ធចង្រៃ
ប្ដីមានតែទុក្ខ ។
បើប្ដីខុសចិត្ត វាគ្មានអាណិត ខេរខឹងច្រអុក
ចាំចងទោសប្ដី ស្រដីកិកកុក ឲ្យមាត់ឲ្យមុខ
វាសវាងរ្វោះរ្វើយ ។
សុខទុក្ខសាំទាំ វាមើលបំណាំ នៅស្ងៀមព្រងើយ
ពុំជួយទុក្ខភ័យ ដោះដៃកន្ដើយ ស្លាប់ដោយរសដោយ
គ្មានចិត្តមេត្រី ។

ចោរីភរិយា ប្រពន្ធពុំជា លបលួចទ្រព្យប្ដី
គ្មានចិត្តករុណា មេត្តាប្រណី របស់ទ្រព្យអ្វី
លក់ចាយអស់ធ្លួន ។
អយ្យាភរិយា ប្រពន្ធពុំជា តម្កើងតែខ្លួន
ចេះតែប្រើប្ដី ឥតបីមានស្ងួន ធ្វើឫកណាំនួន
ទុកប្ដីដូចខ្ញុំ ។
ប្រពន្ធទាំងបី ធ្លាក់ទៅអវចី រងទុក្ខដំណំ
ក្នុងខ្ទះភ្លើងក្ដៅ យូរនៅក្រៀមក្រំ ព្រោះចិត្តខ្លួនធំ
ជាប្ដីអាត្មា។
ឯប្រពន្ធបួន មុខនោះគួរស្ងួន យកជាភរិយា
នឹងកើតរបស់ កេរ្ដិ៍យសសក្ដា ថ្កើងពូជពង្សា
សោយសុខថេរឋិត។
សំដែងបរិយាយ ភរិយាទាំងឡាយ ប្រាំពីរចរិត
ទាំងជួរទាំងជា ពណ៌នាពោលពិត ចែងចប់ពិនិត្យ
តាមអដ្ឋកដា ។

## សេចក្ដីសង្គ្រោះរបស់ស្វាមីទៅលើភរិយា

កតមេហី បញ្ចតី- ហិ សាមិកា
ភរិយាស- ង្គហាធម្មា ប្រែតាមអត្ថា-
ធិប្បាយបាលី ។
ថាប្រុសឯណា នឹងមានភរិយា លោកឲ្យចេះក្ដី
ទាំងប្រាំចំពោះ សង្គ្រោះចិត្តប្ដី ប្រពន្ធប្រក្រតី
ដូចធម៌សម្ដែង ។
បើប្ដីឯណា ពុំកាន់កិរិយា ទាំងប្រាំនេះឯង
ហៅប្ដីទុរជន ជួលន់ក្រៃលែង ចេះតែកំហែង
ចិត្តប្រពន្ធពិត ។
បើប្ដីកាន់ច្បាប់ ទាំងប្រាំនេះខ្ជាប់ ហៅប្ដីសុចរិត
បម្រុងភរិយា ដោយនាក្រមក្រឹត្យ ប្រសើរពេកពិត
ឥតអ្វីផ្ទឹមឡើយ ។
អស់ប្រុសទាំងឡាយ ចូរចាំអធិប្បាយ ច្បាប់នេះជាត្រើយ
ទុកគ្រប់ប្រុសប្រាណ កុំមានកន្តើយ មានប្រពន្ធហើយ
ជាសុខសម្រាន្ត ។
មួយគឺហៅប្ដី ឲ្យប្រើស្រដី នឹងប្រពន្ធមាន
ពាក្យទន់ពិរោះ ស្មើស្មោះដោយក្សាន្ត សរសើររាប់អាន
តាមស័ព្ទវាចា ។
មួយគឺប្រពន្ធ ខុសឆ្គងស្រាលធ្ងន់ កុំជេរផ្ដាសា
ទាត់ធាក់ដៀលដំ ដូចខ្ញុំអាត្មា កុំស្ដីដើមថា
ឲ្យឮសាយស័ព្ទ ។
មួយគឺបានធន ប្រគល់ប្រពន្ធ ទុកដាក់រណ្ដាប់
ទាំងគ្រឿងអាហារ ជាការស្រីផ្ដាប់ រៀបចំសម្រាប់
ថែទាំរក្សា ។
មួយគឺកុំផ្ចង់ កុំខំតែប- ង្កើតកូនហើយថា
ប្រពន្ធសុខចិត្ត ឲ្យគិតប្រាថ្នា រួសរកទ្រព្យា
សម្រាប់ឲ្យផង។
មួយគឺឲ្យចាប់ ស្រឡាញ់ឲ្យខ្ជាប់ កុំជិនណាយហោង
បើមានប្រពន្ធ ទៀតកុំប៉ុនប៉ង ស្រឡាញ់ស្នេហ៍ស្នង

ឲ្យស្មើមុខឡើយ ។

សម្តែងសេចក្តី គ្រប់ប្រាំវថី ចែងចប់ស្រេចហើយ
ឲ្យអស់ប្រុសផង ចាំចងជាត្រើយ ផ្ទង់កុំកន្តើយ
ចោលច្បាប់បុរាណ។

បើប្រុសឯណា ពុំផ្ទង់ចិន្តា ដូចធម៌ទូន្មាន
នៅនឹងភរិយា គ្មានជាសុខសាន្ត ហិនហោចធនធាន
ទាស់ទែងលែងគ្នា ។

ឯវិស័យចិត្ត អស់ស្រីផងពិត មានក្តីប្រាថ្នា
អំពើទាំងប្រាំ នេះចាំចិន្តា គ្រប់ចិត្តភរិយា
នៅនាលោកិយ ។

បើខ្វះអំពើ ណាមួយហើយតើ ប្រពន្ធថាប្តី
ចិត្តពុំត្រូវត្រង់ ពុំគង់មេត្រី តូចចិត្តស្វាមី
អាក់អន់ពុំស្មោះ ។

លោកឲ្យប្រុសផង គន់គិតស្ងួនគ្រង ផ្ទង់ចិត្តសង្គ្រោះ
ប្រពន្ធឲ្យគិត ដោយក្រិត្យប្រាំនោះ ប្រពន្ធក៏ស្មោះ
ចិត្តចូលមូលឯង ។

កុំគិតតែយក ប្រពន្ធមានមក គ្រាន់ឱបប្រលែង
បង្កើតតែកូន សោះសូន្យធនធេង លោកឲ្យគិតក្រែង
ដំណៀលនិន្ទា ។

ធម្មតាជាប្តី បានទ្រព្យធនអ្វី ឬយសសក្តា
តែងនៅសុខសឹង- ទីពឹងផងគ្នា ព្រោះត្បិតភរិយា
កាន់ក្តីសុចរិត ។

អំពើច្នេះហោង ឲ្យអស់ប្រុសផង ចងចាំក្នុងចិត្ត
តាមធម៌ទូន្មាន គ្រប់ប្រាណប្រុសពិត ទុកជាក្រមក្រឹត្យ
ច្បាប់ច្បាស់តទៅ ។

អង្គអញរចនា សេចក្តីកាព្យា តាមច្បាប់ទុកនៅ
ក្នុងព្រះបាលី សេចក្តីជ្រាលជ្រៅ ពុំហ៊ានសៅដៅ
លើកលែងងាយដោយ។

ឧស្សាហ៍ខំប្រុង ប្រែរករើសក្នុង គម្ពីរនិកាយ
អដ្ឋកថា ដីកាបរិយាយ និបាតទាំងឡាយ
មកផ្សំស្រដី ។

ជាច្បាប់ទុកត ដំណឹងតំណ ដំណើរស្ត្រី

ឲ្យជាក់ប្រាកដ ដោយបទបាលី គ្រាន់អស់ប្រុសស្រី
រើសរៀនរកផ្លូវ។
ច្បាប់នេះប្រសើរ ដំណឹងដំណើរ ទំនងនេះកូវ
ជាច្បាប់ប្រាកដ ដោយបទទ្រឹមត្រូវ គួរយើងឥឡូវ
ប្រតិបត្តិរក្សា ។
គួររៀនឲ្យស្ទាត់ ឲ្យចាំរត់មាត់ ដាក់ក្នុងចិន្តា
គ្រាន់នឹងប្រិតប្រៀន បង្រៀនអាត្មា តាមដោយគាថា
នេះឯងតទៅ ។
ចែងចប់អធិប្បាយ ដោយអត្ថបរិយាយ សូរេចថ្ងៃសៅរ៍
ប្រាំបីរោចឯ នាខែមាឃនៅ ឆ្នាំរកាត្រូវ
នព្វស័កស្រេចហោង ។

# **ចប់**